# ពិធីមើលតម្រាហង្ស




+បើប្រុសឱ្យរាប់អាយុពេញ  គឺឆ្នាំជូតលេខ១ ឆ្នាំឆ្លូវលេខ២ ទៅដល់លេខ៨ បើអាយុមិនពេញ ឆ្នាំឱ្យកាត់មួយឆ្នាំចេញ ។

-ឧទាហរណ៍ : យុជន "ក"អាយុ២៤ឆ្នាំ នៅខ្វះ២ខែ ទើបគ្រប់២៤ឆ្នាំ ដូច្នេះឱ្យកាត់មួយឆ្នាំចេញ នៅអាយុពេញ២៣ឆ្នាំ ។

+បើស្រី ឱ្យរាប់ឆ្នាំជូតលេខ៥ ឆ្នាំឆ្លូវលេខ៦ ហើយឱ្យកាត់មួយឆ្នាំចេញដូចគ្នា យកអាយុពេញ ហើយឱ្យទាយតាមទំនាយខាងក្រោម :

+បើត្រូវត្រង់លេខ១ ទំនាយថានៅដើមឆ្នាំ និងត្រូវមានលាភចូល លុះដល់កណ្តាលឆ្នាំនឹងមាន សេចក្តីរំខានចិត្ត ដោយមានបាត់បង់ទ្រព្យសម្បត្តិខ្លះៗ លុះដល់ចុងឆ្នាំនឹងបានសុខ ទ្រព្យរបស់ដែលបាត់នឹង ត្រូវបានមកវិញ ។

+បើត្រូវត្រង់លេខ២ ទំនាយថា នឹងកើតការក្តៅក្រហាយក្នុងចិត្ត ព្រោះគំនិតពុំបានគិតមុខ ក្រោយ ញាតិមិត្ត ក្រុមគ្រួសារបង្ករឿងរ៉ាវ លុះដល់ពាក់កណ្តាលឆ្នាំទើបបានសុខ គោលបំណងប៉ងយូរមក

ហើយនឹងត្រូវបានសម្រេច តែលោកអ្នកគួរកុំធ្វើដំណើរទៅកាន់ទីឆ្ងាយចូរប្រយ័ត្នមានគ្រោះថ្នាក់ ដោយសារអគ្គីភ័យ ។

+បើត្រូវត្រង់លេខ៣ ទំនាយថាដើមឆ្នាំនឹងត្រូវមានលាភចូល តែគួរកុំសេពគប់មនុស្សពាល ស្រីញីក្រៅផ្ទះនាំឱ្យកើតក្តីក្តៅក្រហាយដល់ខ្លួន ចូរប្រយ័ត្នកុំធ្វើដំណើរយប់ព្រលប់ លុះដល់ចុងឆ្នាំទើបបានសេចក្តីសុខគ្រប់ប្រការ ។

+បើត្រូវត្រង់លេខ៤ ទំនាយថា ដើមឆ្នាំនឹងមានគ្រោះអាសន្នដល់ខ្លួន និងមានមនុស្សបង្ករឿងរ៉ាវ លុះដល់កណ្តាលឆ្នាំទើបបានល្អ លាភចូលជាហូរហែ រកស៊ីជួញដូរនិងបានផលគាប់ប្រសើរ តែប្រយ័ត្ននឹងមានអ្នកធំរករឿងចាប់កំហុស ។

+បើត្រូវត្រង់លេខ៥ ទំនាយថានឹងត្រូវបានជួបគូរព្រេងដ៏គាប់ប្រសើរ ឬត្រូវបានរបស់ថ្មីថ្មោងដែលខ្លួនមិនធ្លាប់មាន ប៉ុន្តែចូរប្រយ័ត្នមនុស្សសំបុរខ្មៅឱ្យទុក្ខទោសដល់គ្រួសារ លុះដល់ចុងឆ្នាំទើបបានល្អប្រសើរឡើងវិញ ។

+បើត្រូវត្រង់លេខ៦ ទំនាយថាដើមឆ្នាំនឹងត្រូវមានគ្រោះកាចធំ ឬត្រូវភ័យព្រួយដោយសារពាក្យសម្តីរបស់ខ្លួន ចូរប្រយ័ត្នកុំយកអាសារអ្នកដទៃ លុះដល់កណ្តាលឆ្នាំទើបបានល្អគាប់ប្រសើរឡើងវិញ ត្រូវបានអ្នកធំជួយយកអាសារផ្តល់ផលប្រយោជន៏យ៉ាងធំឱ្យ ចូរប្រយ័ត្នចុងឆ្នាំងនឹងមានមនុស្សនាំរឿងចូលផ្ទះនាំឱ្យខូចខាតលាភរបស់ខ្លួន ។

+បើត្រូវត្រង់លេខ៧ ទំនាយថាដើមឆ្នាំនឹងមានរាសីខ្ពស់ ត្រូវបានបុណ្យសក្តិធំ ធ្វើរបរជំនួញនឹងបានផលចំណេញ កណ្តាលឆ្នាំមានការក្តៅក្រហាយចិត្ត ប្រយ័ត្នមនុស្សខូចជិតខាងច្រណែនផ្តន្ទាឈ្នានីស លុះចុងឆ្នាំនឹងត្រូវបានលាភជើង២ និងជើង៤ ។

+បើត្រូវត្រង់លេខ៨ ទំនាយថានឹងមានគ្រោះអាក្រក់ ដោយសារគេឆ្លើយមួលបង្កាច់បង្ខូច លុះដល់កណ្តាលឆ្នាំនឹងមានអ្នកធំជួយជ្រោមជ្រែង ជួយផ្តល់កិច្ចការឱ្យបានរីកចំរើន លុះចុងឆ្នាំនឹងត្រូវបានលាភចូលផ្សេងៗ ។